Australian Government | ParentsNext

# ការទាញយកផលប្រយោជន៍ឱ្យបានច្រើនបំផុត ពីផែនការចូលរួមរបស់អ្នក



## ទីប្រឹក្សាសេវា ParentsNext របស់អ្នក នឹងជួយអ្នកបង្កើតផែនការចូលរួម។

ផែនការនេះនឹងជួយអ្នកកំណត់គោលដៅអប់រំ និងការងាររបស់អ្នក និងចាប់យកជំហានបន្ទាប់ក្នុងការត្រៀមរកការងារ នៅមុនពេលកូនដែលមានអាយុតិចជាងគេបង្អស់ចាប់ផ្តើមចូលរៀន។

ផែនការរួមមាន៖

- គោលដៅសិក្សា និងការងាររបស់អ្នក
- សកម្មភាពតម្រូវការឱ្យរាយការណ៍ និងការណាត់ជួប ដែលអ្នកបានយល់ព្រមធ្វើ។

**សកម្មភាពនឹងកែសម្រួលឱ្យសមស្រប** ទៅនឹងសេចក្តីត្រូវការរបស់អ្នក និងគ្រួសាររបស់អ្នក។ សកម្មភាពទាំងនេះ រួមមាន៖

- ការកសាង **បំណិនត្រៀមរកការងារ** ដូចជាការសរសេរប្រវត្តិរូបសង្ខេប ការហាត់ធ្វើសម្ភាសន៍ ឬក៏ការទទួលបានអាជ្ញាប័ណ្ណ
- **បទពិសោធន៍ការងារ** ឬក៏ **ការស្ម័គ្រចិត្ត**
- **វគ្គបណ្តុះបណ្តាល TAFE ឬក៏សាកលវិទ្យាល័យ**
- **ការទទួលបានការគាំទ្រ** ដើម្បីទទួលយកសេវានានាតាមមូលដ្ឋាន។

ប្រសិនបើអ្នកកំពុងសិក្សា ធ្វើការងារ ឬក៏ធ្វើការស្ម័គ្រចិត្ត សកម្មភាពទាំងនេះនឹងដាក់បញ្ចូលជាសកម្មភាពនៅក្នុងផែនការរបស់អ្នក **អ្នកមិនបាច់ធ្វើសកម្មភាពបន្ថែមទេ។**

ប្រសិនបើអ្នកត្រូវការជំនួយហិរញ្ញវត្ថុ សម្រាប់កិច្ចការនានាទាក់ទងនឹងសកម្មភាពរបស់អ្នក សូមសួរអ្នកផ្តល់សេវារបស់អ្នកអំពីថាតើអ្នកអាចមានសិទ្ធិទទួលជំនួយនៅក្រោមមូលនិធិនៃការចូលរួម (Participation Fund)។

## អ្នកគ្រប់គ្រងផែនការចូលរួមរបស់អ្នក

- ✓ នៅពេលអ្នកធ្វើផែនការថ្មីជាមួយទីប្រឹក្សានៃសេវា ParentsNext របស់អ្នក អ្នកមានរយៈពេល 10ថ្ងៃធ្វើការដើម្បីគិតអំពីផែនការនេះ នៅមុនពេលចុះហត្ថលេខា។
- ✓ ប្រសិនបើសកម្មភាពមួយមិនដំណើរការសម្រាប់អ្នក សូមពិភាក្សាជាមួយទីប្រឹក្សារបស់អ្នកឱ្យប្តូរវា។
- ✓ សូមប្រាប់ទីប្រឹក្សារបស់អ្នក ប្រសិនបើស្ថានភាពរបស់អ្នកមានការផ្លាស់ប្តូរ និងប៉ះពាល់ដល់សមត្ថភាពរបស់អ្នកដើម្បីអនុវត្តតាមផែនការរបស់អ្នក (ឧទាហរណ៍ ប្រសិនបើអ្នកគ្មានយានជំនិះ ឬក៏ធ្វើដំណើរបាន)។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ dese.gov.au/parentsnext